**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ: ៥៧ ប្រ ក កបរ**

# ប្រកាស

## ស្ដីពី

## ការដាក់មេធាវីរាជរដ្ឋាភិបាលឱ្យស្ថិតនៅក្រោម
## ការគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់

-យោងតាមការងារចាំបាច់

## សម្រេច

**ប្រការ ១ :** ត្រូវបានដាក់មេធាវីរាជរដ្ឋាភិបាល ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់។

**ប្រការ ២:** ត្រូវបានផ្ទេរមន្ត្រីនៃលេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល ឱ្យទៅបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ ក្នុងក្របខ័ណ្ឌទីស្ដីការគណៈរដ្ឋមន្ត្រី។

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា

**ប្រការ ៣ :** មេធាវីរាជរដ្ឋាភិបាលមានភារកិច្ចៈ

-ទទួល និងពិនិត្យ ស្រាវជ្រាវ លើរាល់ពាក្យបណ្តឹងសុំអន្តរាគមន៍មករាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌពាក់ព័ន្ធ នឹងវិវាទកិច្ចការច្បាប់និងតុលាការ សម្រាប់លើកយោបល់តាមរយៈអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ ជូនរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិង សម្រេច

-គ្រប់គ្រងកិច្ចការបណ្តឹងទាំងឡាយក្នុងក្របខ័ណ្ឌបណ្តឹងដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់រាជរដ្ឋាភិបាល

-តាមដានពិនិត្យ និងស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងពាក្យបណ្តឹងទាំងឡាយ ដែលថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី និងប្រមុខរាជរដ្ឋាភិបាលប្រគល់ជូន

-ទទួលភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី និងប្រមុខរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៤ :** រាល់ការចំណាយរបស់មេធាវីរាជរដ្ឋាភិបាល ជាបន្ទុករបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់។

**ប្រការ ៥ :** ប្រកាសលេខ ១៥៦ ប្រក ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើតលេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាលនិង បទប្បញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦ :** អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងមេធាវីរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ០៥ ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល:**

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ៦

-ឯកសារ កាលប្បវត្តិ

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា